ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ៧៣៩ ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបេក្ខជនតាមប្រភេទនៃកម្រិតសិក្សានីមួយៗ ឱ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧

យោងតាមស្មារតីអង្គប្រជុំស្តីពីការកំណត់កាលបរិច្ឆេទ និងកំណត់ចំនួនបេក្ខជនដែលត្រូវជ្រើសរើសតាមប្រភេទនៃកម្រិតសិក្សានីមួយៗ ឱ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងថា នៅក្នុងឆ្នាំសិក្សា២០១៦-២០១៧ ខាងមុខនេះ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នឹងធ្វើការជ្រើសរើសបេក្ខជនតាមប្រភេទនៃកម្រិតសិក្សានីមួយៗ ឱ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមគោលការណ៍ដូចមាននៅក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះគ្រឹះស្ថាន | កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ | | កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | | កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ | | កម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | | កាលបរិច្ឆេទជ្រើសរើស ប្រឡងជ្រើសរើស តេស្តជ្រើសរើស និងចុះឈ្មោះចូលរៀន |
|---|---|---|---|---|---|---|---|---|---|---|
| | | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | |
| ១ | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ១៦០ | - | - | ៥៤០ | - | ៥៨០ | - | - | ជូនដំណឹងពេលក្រោយ |
| ២ | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៤០ | - | - | ៣០០ | - | ៥០០ | - | ២៥ | ១៥ កុម្ភៈ ២០១៧ |
| ៣ | វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ១២០ | - | ២៤០ | ៥០០ | ២៤០ | ៥០០ | - | ៩០ | ២៦ កញ្ញា ២០១៦ |
| ៤ | វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ១០០ | - | ៣៦០ | ២០០ | ២២៥ | ៣០០ | - | ៦០ | ២៥ តុលា ២០១៦ |
| ៥ | វិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា | ៣០០ | - | - | ២៧០ | ៣៦០ | ៥៤០ | - | - | ២៥ វិច្ឆិកា ២០១៦ |
| ៦ | វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម | ២៥០ | ២០០ | ៣២០ | ២០០ | ២០០ | ១០០ | - | - | ០៨ វិច្ឆិកា ២០១៦ |
| ៧ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង | ១០០ | - | ១០០ | ៥០ | ១០០ | ៥០ | - | - | ០៣ តុលា ២០១៦ |
| ៨ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត | ៩៥ | - | ៩៥ | ១០០ | ១០០ | ១២០ | - | - | ០៤ វិច្ឆិកា ២០១៦ |
| ៩ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ | ២៧០ | - | ២០០ | ២០០ | ១៧៥ | ១៨០ | - | - | ២៦ ធ្នូ ២០១៦ |
| ១០ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប | ៨០ | - | ១០០ | ៦០ | ២០ | - | - | - | ១៦ ធ្នូ ២០១៦ |

| ល.រ | ឈ្មោះគ្រឹះស្ថាន | កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ | | កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស | | កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ | | កម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | | កាលបរិច្ឆេទជ្រើសរើស ប្រឡងជ្រើសរើស តេស្តជ្រើសរើស និងចុះឈ្មោះចូលរៀន |
|---|---|---|---|---|---|---|---|---|---|---|
| | | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | |
| ១១ | វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង | ២៤០ | - | ២៤០ | ១០០ | ១៨០ | ៦០ | - | - | ០១ វិច្ឆិកា ២០១៦ |
| ១២ | វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង | ២០០ | - | ១២០ | - | - | - | - | - | ២១ វិច្ឆិកា ២០១៦ |
| ១៣ | វិទ្យាស្ថានពហុបច្ចេកទេស ខេត្តព្រះសីហនុ | ១៣៥ | - | ១៨០ | ១៨០ | ៦៥ | ២០០ | - | - | ១៧ វិច្ឆិកា ២០១៦ |
| ១៤ | សាលាមធ្យមសិក្សាបច្ចេកទេសហ្ស៊ី វ៉េ សេ | ៧០ | ២០ | ១០០ | ៣០ | - | - | - | - | ២៨ តុលា ២០១៦ |
| ១៥ | មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ | ១០០ | - | ២៣០ | - | - | - | - | - | ២៨ វិច្ឆិកា ២០១៦ |
| ១៦ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ | ៦០ | - | ១២០ | ៩០ | - | - | - | - | ១៩ ធ្នូ ២០១៦ |
| ១៧ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម | ១០០ | - | ១០០ | - | - | - | - | - | ០២ ធ្នូ ២០១៦ |
| ១៨ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តពោធិ៍សាត់ | ៨០ | - | ៧០ | - | - | - | - | - | ១២ ធ្នូ ២០១៦ |
| ១៩ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ | ៦០ | - | ១០០ | - | - | - | - | - | ៣០ ធ្នូ ២០១៦ |
| ២០ | ការដ្ឋានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប | ១៩២ | - | ៦០ | ២០ | - | - | - | - | ១១ វិច្ឆិកា ២០១៦ |
| ២១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ | ១២៥ | - | ១២៥ | - | - | - | - | - | ១២ តុលា ២០១៦ |
| ២២ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកោះកុង | ៦០ | - | ៣០ | - | - | - | - | - | ២១ ធ្នូ ២០១៦ |
| ២៣ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល | ៧០ | - | ៧០ | - | - | - | - | - | ០៨ ធ្នូ ២០១៦ |
| ២៤ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង ព្រែកូនខ្លា | ៩០ | - | ៨០ | - | - | - | - | - | ២៣ ធ្នូ ២០១៦ |
| ២៥ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង | ៦០ | - | ៦០ | - | - | - | - | - | ២៨ ធ្នូ ២០១៦ |
| ២៦ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី | ៧៥ | - | - | - | - | - | - | - | ១៩ តុលា ២០១៦ |
| ២៧ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី | ៣០ | - | - | - | - | - | - | - | ២១ តុលា ២០១៦ |
| ២៨ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្ទឹងត្រែង | ៦០ | - | ៤០ | - | - | - | - | - | ២០ តុលា ២០១៦ |
| ២៩ | វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច | - | - | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ១០ តុលា ២០១៦ |
| ៣០ | វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា | - | - | - | - | - | ៦០០ | - | - | ០៥ មករា ២០១៧ |
| ៣១ | វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា | - | - | ៥០ | ២០០ | ១០០ | ៧០០ | - | ៨០ | ២៣ មីនា ២០១៧ |
| ៣២ | វិទ្យាស្ថានខ្មែរជំនាន់ថ្មី | - | - | ៧០ | ២២៧ | ២៧០ | ៧៤០ | ១៥ | ៤៥ | ២៧ មករា ២០១៧ |
| ៣៣ | វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ | | | ២០ | ១០០ | ៥០ | ៣០០ | - | - | ១៨ មករា ២០១៧ |
| ៣៤ | វិទ្យាស្ថានអាស៊ី កម្ពុជា | ២០ | ២០០ | ៣០ | ៥០ | ៣០ | ១០០ | - | - | ១០ កុម្ភៈ ២០១៧ |
| ៣៥ | វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត | - | - | ១០០ | ២០០ | ២០០ | ៥០០ | - | - | ១៤ តុលា ២០១៦ |
| ៣៦ | វិទ្យាស្ថានបច្ចេកវិទ្យាភ្នំពេញ | - | - | ៥០ | ៦០ | ១៥០ | ១៤០ | - | - | ២៦ តុលា ២០១៦ |
| ៣៧ | វិទ្យាស្ថានបច្ចេកទេសជួសជុលរថយន្ត | - | - | ១៥ | ៩៥ | - | - | - | - | ២៤ កុម្ភៈ ២០១៧ |

| ល.រ | ឈ្មោះគ្រឹះស្ថាន | កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ | | កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | | កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ | | កម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | | កាលបរិច្ឆេទជ្រើសរើស ប្រឡងជ្រើសរើស តេស្តជ្រើសរើស និងចុះឈ្មោះចូលរៀន |
|---|---|---|---|---|---|---|---|---|---|---|
| | | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | អាហារូបករណ៍ | បង់ថ្លៃ | |
| ៣៨ | វិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្សអាស៊ីនៅកម្ពុជា | - | - | ១០០ | - | - | - | - | - | ០៧ ធ្នូ ២០១៦ |
| ៣៩ | វិទ្យាស្ថានអាជីវកម្មអន្តរជាតិ | - | - | ២៥០ | ២៥០ | - | - | - | - | ២៦ វិច្ឆិកា ២០១៦ |
| ៤០ | វិទ្យាស្ថានជំនាញគណនេយ្យ | - | - | ៦០ | ២០០ | - | - | - | - | ០៦ កុម្ភៈ ២០១៧ |
| ៤១ | វិទ្យាស្ថានវ៉ាន់ដាបាត់ដំបង | - | - | ២០ | ៣០០ | - | - | - | - | ២២ មករា ២០១៧ |
| ៤២ | វិទ្យាស្ថានឯកទេសកុំព្យូទ័រ និងភាសា | ៥០ | - | ២០០ | ៥០ | - | - | - | - | ៣០ មីនា ២០១៧ |
| ៤៣ | វិទ្យាស្ថានគុណភាពការងារកម្ពុជា | - | ២០០ | - | ១ ០០០ | - | - | - | - | ២៣ កញ្ញា ២០១៦ |
| ៤៤ | មជ្ឈមណ្ឌលក្រមង៉ុយបច្ចេកសាស្ត្រ | - | - | - | ៥០ | - | - | - | - | ០៩ កញ្ញា ២០១៦ |
| ៤៥ | សាលាបច្ចេកទេស ដុនបូស្កូ ភ្នំពេញ | ៧០ | - | ២០០ | - | - | - | - | - | ០២ កញ្ញា ២០១៦ |
| ៤៦ | សាលាបច្ចេកទេស ដុនបូស្កូ ខេត្តព្រះសីហនុ | - | - | ៣៤០ | - | - | - | - | - | ០២ កញ្ញា ២០១៦ |
| ៤៧ | សាលាបច្ចេកទេស ដុនបូស្កូ កែប | - | - | ១០០ | - | - | - | - | - | ០២ កញ្ញា ២០១៦ |
| ៤៨ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដុនបូស្កូ ផ្នែកនារី | - | - | ៨០ | - | - | - | - | - | ០២ កញ្ញា ២០១៦ |
| ៤៩ | សាលាជាងឈើ អ៊ី អែស កា | ២៥ | - | - | - | - | - | - | - | ២៩ កញ្ញា ២០១៦ |
| ៥០ | វិទ្យាស្ថាន ប៉េ អេស អ៊ី | ១០០ | - | ៥០ | - | ១០០ | - | - | - | ០៨ សីហា ២០១៦ |
| ៥១ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈហេបភីច័ន្ទតារា | ៤០ | - | - | - | - | - | - | - | ១៥ កញ្ញា ២០១៦ |
| សរុប | | ៣ ៦២៧ | ៦២០ | ៤ ៩២៥ | ៥ ៦៧២ | ២ ៦១៥ | ៦២៦០ | ៦៥ | ៣៥០ | |

## ១. លក្ខខណ្ឌចុះឈ្មោះជ្រើសរើស

- កម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ បេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស បេក្ខជនដែលបានរៀនចប់មធ្យមសិក្សាទុតិយភូមិ (ប្រឡងធ្លាក់) ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ បេក្ខជនដែលបានរៀនចប់មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៩) ឬបានបញ្ចប់វគ្គស្ពានចម្លងបន្តជំនាញ ឬកម្រិតសមមូល។

## ២. សំណុំលិខិតរបស់បេក្ខជន

- ពាក្យសុំចូលរៀននៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈចំនួន ០១ ច្បាប់
- ចំពោះកម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ ឬសញ្ញាបត្រដែលមានតម្លៃស្មើចំនួន ០១ ច្បាប់
- ចំពោះកម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ បេក្ខជនត្រូវមានព្រឹត្តិបត្រពិន្ទុនៃការប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ ឬសញ្ញាបត្រដែលមានតម្លៃស្មើចំនួន ០១ ច្បាប់

- ចំពោះកម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស បេក្ខជនត្រូវមានព្រឹត្តិបត្រពិន្ទុនៃការប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ ឬសញ្ញាបត្រដែលមានតម្លៃស្មើចំនួន ០១ ច្បាប់
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ បេក្ខជនត្រូវមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬលិខិតបញ្ជាក់ការសិក្សា ថាបានរៀនចប់ថ្នាក់ទី៩ នៃសាលាចំណេះទូទៅ ឬបានបញ្ចប់វគ្គស្ពានចម្លងបន្តជំនាញ ឬកម្រិតសមមូលចំនួន ០១ ច្បាប់
- ប្រវត្តិរូបដែលមានបិទរូបថត (៤x៦ ស.ម) ចំនួន ០២ ច្បាប់ (ប្រវត្តិរូបត្រូវមានបញ្ជាក់ពីនាយកសាលា)
- រូបថតក្នុងពេលថ្មីៗទំហំ (៤x៦ ស.ម) ថតចំពីមុខ គ្មានពាក់វ៉ែនតា និងមានផ្ទៃខាងក្រោយពណ៌សចំនួន ០៣ សន្លឹក

បេក្ខជនជានារី ក្រីក្រ តំបន់ដាច់ស្រយាល និងជនជាតិភាគតិច និងជនពិការត្រូវបានចាត់ទុកជាអាទិភាពក្នុងការទទួលអាហារូបករណ៍។ ចំពោះបេក្ខជនក្រីក្រ តំបន់ដាច់ស្រយាល និងជនជាតិភាគតិច ត្រូវមានឯកសារពីរបន្ថែមទៀត គឺសេចក្តីបញ្ជាក់ត្រឹមត្រូវពីរដ្ឋអំណាចថ្នាក់ឃុំ ឬសង្កាត់អំពីភាពក្រីក្រ តំបន់ដាច់ស្រយាល និងជនជាតិភាគតិច និងប័ណ្ណគ្រួសារថតចម្លងតាមផ្លូវច្បាប់ចំនួន ០១ ច្បាប់។

គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនីមួយៗមានបំណងធ្វើការជ្រើសរើស ត្រូវធ្វើសេចក្តីជូនដំណឹងលម្អិតដោយខ្លួនឯងរបស់ខ្លួន។

ចំពោះព័ត៌មានផ្សេងៗទៀត បេក្ខជនអាចធ្វើការទំនាក់ទំនងផ្ទាល់ជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនីមួយៗ ដែលខ្លួនមានបំណងចូលរៀន។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
-គ្រប់សាលារាជធានី-ខេត្ត
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
-គ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-ឯកសារ-កាលប្បវត្តិ